ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ៩៦៩/០៤-១១-២០១៣

**សាលដីកា**

លេខៈ១៦ក្រVI(ជ)/១១-៤-២០១៤

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នារសៀលថ្ងៃទី១១-៤-២០១៤ ដែលមានសមាសភាពដូចតទៅ:

**<u>សមាសភាពក្រុមប្រឹក្សា</u>**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ៩៦៩ ចុះថ្ងៃទី០៤-១១-២០១៣៖

១-ជនជាប់ចោទឈ្មោះ [redacted] វេង ហៅ [redacted] សុខហេង ហៅ លឹម វេង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅកំណើតស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅមុនពេលចាប់ខ្លួនផ្ទះជួល [redacted] ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](ស) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០០៨ ឃុំខ្លួនចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៨ នៅពន្ធនាគារម១

មេធាវីការពារលោក [redacted] ចន្ថា

ជាប់ចោទពីបទ: ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា និង ប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចក្រោយនាគពន្ធ័ សង្កាត់អូរឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋនិងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និង គ្រប់រំសេវ ។

**<u>ឯរឿងហេតុមានដូចតទៅ:</u>** ៧០



Scanned with CamScanner

កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ឈ្មោះ [redacted] វេង ហៅ លី សុខហេង ហៅ លឹម វេង បានជិះ ម៉ូតូម៉ាកស្ទេប ពណ៌សលាយខ្មៅ តាមដងផ្លូវលេខ១៥៤ សង្កាត់ផ្សារថ្មីទី៣ ជួបជាមួយកម្លាំងសមត្ថកិច្ចដើរល្បាតក៏បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] វេង ដើម្បីធ្វើការត្រួតពិនិត្យ តែឈ្មោះ [redacted] វេង មិនឈប់ជិះម៉ូតូគេចខ្លួនមកដល់សង្កាត់អូរឬស្សីទី៤ ខណ្ឌ៧មករា ក្រោយនាគពន្ធ័ ឈ្មោះ [redacted] វេង ក៏បានយកកាំភ្លើងខ្លីបាញ់០៥គ្រាប់ទៅលើសមត្ថកិច្ច ហើយសមត្ថកិច្ចក៏បាញ់តបវិញ០២គ្រាប់ ដើម្បីឱ្យឈ្មោះ [redacted] វេង ឈប់ តែឈ្មោះនេះបានជិះម៉ូតូយ៉ាងលឿនគេចខ្លួនបាត់ រហូតដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៨ សមត្ថកិច្ចក៏បានជួបឈ្មោះ [redacted] វេង ហើយបានធ្វើការឃាត់ខ្លួន និង ដកហូតអាវុធខ្លីមួយដើមម៉ាកK៥៩ លេខ៥៩៩៨ បង់មួយគ្រាប់០៨គ្រាប់ ។

រឿងក្តីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ:១៣៨(ក្រ៣) ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ មានខ្លឹមសារដូចខាងក្រោម៖

១-ផ្តន្ទាទោសឈ្មោះ [redacted] វេង ហៅ លឹម វេង ហៅ លី សុខហេង ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះជួល [redacted] ដាក់ពន្ធនាគារសរុបកំណត់១១ឆ្នាំ(១០+១)(ដប់មួយឆ្នាំ) ដោយគិតបន្តពីសាលក្រមមុននិងពិន័យជាប្រាក់ចំនួន២.០០០.០០០៛០០ (ពីរលានរៀល) សំរាប់ដាក់ចូលថវិការដ្ឋ ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា និងបទ ប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅចំណុចក្រោយនាគពន្ធ័ សង្កាត់អូរឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

២-វត្ថុតាងមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ:៤១៧ អយយ ចុះថ្ងៃទី២៣-១២-២០០៨ មាន:

-អាវុធខ្លីម៉ាក K ៥៩ លេខ៥៩៩៨ បង់មួយ មានគ្រាប់០៨គ្រាប់ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

-កាំបិតកែពណ៌សមួយត្រូវរឹបអូសបំផ្លាញចោល ។

-ម៉ូតូម៉ាកស្ទេបពណ៌ខ្មៅលាយសលេខតួ-លេខម៉ាស៊ីន ៥០២៧៦៥ គ្មានស្លាកលេខ ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥-១២-២០០៩ ប្រកាសជាសាធារណៈថ្ងៃទី៣០-១២-២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វេង ហៅ លឹម វេង ហៅ លី សុខហេង មេធាវីការពារជនជាប់ចោទឈ្មោះកញ្ញាបណ្ឌិត [redacted] នារី ជនរងគ្រោះឈ្មោះ [redacted] វិសាល បើកផ្លូវប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។/

៧១

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខៈ១៣(ឋ) ចុះថ្ងៃទី១២-១០-២០១០ របស់សាលាឧទ្ធរណ៍ មានខ្លឹមសារដូចខាងក្រោមៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខៈ៣១ ចុះថ្ងៃទី១២-០១-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] វេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខៈ១៣៨(ក្រ៣) ចុះថ្ងៃទី៣០-១២-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០១-១០-២០១០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១២-១០-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វេង ។ បើកឱ្យសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខៈ២៣៨ ចុះថ្ងៃទី២៧-៩-២០១៣ របស់តុលាការកំពូល មានខ្លឹមសារដូចខាងក្រោមៈ

១-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខៈ១៧៩ ចុះថ្ងៃទី២៦-៧-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វេង ទុកជាត្រឹមត្រូវ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខៈ១៣(ឋ) ចុះថ្ងៃទី១២-១០-២០១០ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែផ្នែកផ្តន្ទាទោសជនជាប់ចោទ [redacted] វេង ពីបទៈប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ត្រូវបដិសេធចោលជាអសារបង់ ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខៈ១៧៤ ចុះថ្ងៃទី២៨-៨-២០១២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ លើបទចោទប្រកាន់ចំពោះជនជាប់ចោទ [redacted] វេង ពីបទៈ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០-៩-២០១៣ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី២៧-៩-២០១៣ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋានបន្ថែមចុះថ្ងៃទី២០-៣-២០១៤ របស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបរឿងក្តី

-ជនជាប់ចោទឈ្មោះ [redacted] វេង ឆ្លើយថាៈ នៅថ្ងៃកើតហេតុ ខ្លួនមិនបានបាញ់សមត្ថកិច្ចទេ ពេលសមត្ថកិច្ចដេញចាប់ខ្លួន ហើយខ្លួនជិះម៉ូតូតែម្នាក់ឯងទេ ។ ដោយសមត្ថកិច្ចជិះម៉ូតូស្លៀកពាក់ស៊ីវិល ទើបខ្លួនមិនស្គាល់ ។ នៅនាគពន្ធ័ខ្លួនអត់មានបាញ់ទេ ។ ពេលសមត្ថកិច្ចចាប់ខ្លួនៗមានកាំភ្លើងៗមាន០៨គ្រាប់ ។ កាំភ្លើងទិញពីគេពេលខ្លួនធ្វើប៉ូលីសគ្រឿងញៀន តែខ្លួនឈប់ធ្វើហើយ មិនទាន់យកកាំភ្លើងឱ្យសមត្ថកិច្ច ទុក៕/



Scanned with CamScanner

ការពារខ្លួនសិន ។ សមត្ថកិច្ចឃាត់ខ្លួនខែ១២ ឆ្នាំ២០១២ ។ ខ្លួនសំណូមពរសុំឱ្យសាលាឧទ្ធរណ៍ ជួយរកយុត្តិធម៌ ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: សូមសភាព្រហ្មទណ្ឌពិនិត្យនិងសម្រេច តាមការចង្អុលបង្ហាញរបស់តុលាការកំពូល ។

-មេធាវីលោក [redacted] ចន្ថា សន្និដ្ឋានថា: រឿងក្តីនេះត្រូវបានតុលាការកំពូលបង្វិលមកសាលាឧទ្ធរណ៍ សាកសួរអង្កេតឡើងវិញពីកន្លែងកើតហេតុ ។ កន្លងមកកូនក្តីខ្លួនជាមន្ត្រីប៉ូលីសគ្រឿងញៀន តែដោយបញ្ហាសុខភាពក៏ឈប់ធ្វើការងារហើយមិនទាន់បានយកអាវុធទុកឱ្យស្ថាប័នរបស់ខ្លួនទេ ។ ថ្ងៃមួយកូនក្តីខ្លួនជិះម៉ូតូតាមផ្លូវសមត្ថកិច្ចឃើញក៏ដេញចាប់ ។ កូនក្តីខ្លួនទទួលទណ្ឌកម្មចំនួន៦ឆ្នាំហើយពីរឿងប្រើប្រាស់អាវុធខុសច្បាប់ ។ ហេតុនេះសូមក្រុមប្រឹក្សាសម្រេចតាមការចង្អុលបង្ហាញរបស់តុលាការកំពូល ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារដែលពាក់ពន្ធ័

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍**

**<u>យល់ឃើញថា</u>**

១-សំណុំរឿងព្រហ្មទណ្ឌលេខ:៩៦៩ ចុះថ្ងៃទី០៥-១១-២០១៣ របស់សាលាឧទ្ធរណ៍ ត្រូវបានតុលាការកំពូលបង្វិលមកសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ:២៣៨ ចុះថ្ងៃទី២៧-៩-២០១៣ របស់តុលាការកំពូល ដូច្នេះសាលាឧទ្ធរណ៍ ទទួលជំនុំជម្រះបានតាមច្បាប់ ។

២-តុលាការកំពូលបានសម្រេចបង្វិលមកសាលាឧទ្ធរណ៍ ដើម្បីធ្វើការជំនុំជម្រះជាថ្មីឡើង វិញលើបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វេង តែលើបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាប៉ុណ្ណោះ ចំពោះចំណុចដទៃទៀតរបស់សាលដីកាព្រហ្មទណ្ឌលេខ:១៣(ឋ) ចុះថ្ងៃទី១២-១០-២០១០ របស់សាលាឧទ្ធរណ៍ ត្រូវបានតុលាការកំពូលសម្រេចតម្កល់ទុកជាបានការហើយ ដូច្នេះសាលាឧទ្ធរណ៍ ពេលនេះលើកយកតែបទចោទប្រកាន់ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា មកពិចារណាប៉ុណ្ណោះ ។

៣-តាមរបាយការណ៍ និង ការបំភ្លឺរបស់សមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជាក់ថា នៅថ្ងៃទី១៧-១២-២០០៨ វេលាម៉ោង១៧និង៤០នាទី សមត្ថកិច្ចបានចុះល្បាតតាមដងផ្លូវក៏បានជួបនឹងជនសង្ស័យឈ្មោះ [redacted] វេង សមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យដើម្បីធ្វើការត្រួតពិនិត្យ តែជនសង្ស័យពុំបានឈប់អោយត្រួតពិនិត្យទេ គឺបានជិះម៉ូតូគេចខ្លួន ហើយសមត្ថកិច្ចក៏បានដេញតាមរហូតដល់ក្រោយនាគព័ន្ធ

ជនសង្ស័យបានយកអាវុធខ្លីបាញ់លើសមត្ថកិច្ចចំនួន០៥គ្រាប់ ហើយសមត្ថកិច្ចក៏បានបាញ់តបចំនួន២គ្រាប់ ដើម្បីអោយជនសង្ស័យឈប់ តែជនសង្ស័យរត់គេចខ្លួនបាត់ ។ រហូតដល់ថ្ងៃទី២០-១២-២០០៨ សមត្ថកិច្ចក៏បានជួបឈ្មោះ [redacted] វេង ក៏បានឃាត់ខ្លួន និង បានដកហូតបានអាវុធខ្លីមួយដើម និង គ្រាប់ចំនួន៨គ្រាប់ ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វេង បានបញ្ជាក់ថា នៅថ្ងៃទី១៧-១២-២០០៨ វេលាម៉ោង១៧និង៤០នាទី ខ្លួនបានជិះម៉ូតូតាមផ្លូវតែម្នាក់ឯង ស្រាប់តែមានមនុស្សស្លៀកពាក់ស៊ីវិលជិះម៉ូតូឌុបគ្នាមកជិតខ្លួន រួចលូកដៃចាប់ដៃចង្កូតម៉ូតូរបស់ខ្លួនអោយឈប់ តែខ្លួនមិនឈប់ព្រោះខ្លាចជាចោរប្លន់ក៏បានបើកម៉ូតូទៅមុខទៀត ហើយអ្នកនោះក៏បានបើកម៉ូតូដេញតាមខ្លួនទៀតរហូតដល់ក្រោយនាគព័ន្ធ ស្រាប់តែអ្នកជិះម៉ូតូនោះដកកាំភ្លើងខ្លីបាញ់មកលើខ្លួន ខ្លួនភ័យក៏បានបន្ថែមល្បឿនម៉ូតូជិះគេចខ្លួនចេញទៅ តែខ្លួនពុំបានបាញ់កាំភ្លើងទេ ។ លុះដល់ថ្ងៃទី២០-១២-២០០៨ ពេលខ្លួនកំពុងដើរតាមផ្លូវក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

៥-តាមការបំភ្លឺរបស់សមត្ថកិច្ច និង តាមចម្លើយរបស់ជនជាប់ចោទបានបញ្ជាក់អោយឃើញថា កម្លាំងល្បាតរបស់សមត្ថកិច្ចដែលស្លៀកពាក់ស៊ីវិល បានជិះម៉ូតូល្បាត និង បានឃាត់ជនសង្ស័យឈ្មោះ ស៊ិន វេង អោយឈប់ដោយពុំបានបង្ហាញដល់ជនសង្ស័យក៏ដូចជាសាធារណៈជនថា ខ្លួនជាកម្លាំងសមត្ថកិច្ចស្របច្បាប់នោះទេ ទើបធ្វើអោយជនសង្ស័យមិនព្រមឈប់ និង បានបើកម៉ូតូគេចខ្លួនថែមទៀត ដែលការបើកម៉ូតូគេចខ្លួននេះ មិនមានន័យថាជនសង្ស័យរត់គេចពីការត្រួតពិនិត្យរបស់សមត្ថកិច្ចនោះទេ ។ ផ្ទុយទៅវិញជនសង្ស័យឈ្មោះ [redacted] វេង អាចរត់គេចចេញពីអំពើប៉ុនប៉ងប្រព្រឹត្តអំពើល្មើសអ្វីមួយមកលើខ្លួនដូចជាប្លន់ម៉ូតូខ្លួនជាដើម ព្រោះថាមានករណីប្លន់(លួចដោយមានស្ថានទម្ងន់ទោស ដោយសារការប្រើអំពើហិង្សា) ជាច្រើន ដែលជាញឹកញាប់ជនល្មើសតែងតែជិះម៉ូតូកៀរម៉ូតូជនរងគ្រោះអោយឈប់ ឬដួលនិងធ្វើសកម្មភាពប្លន់តែម្តង ។

៦-ក្រោយពីបានបើកម៉ូតូរត់គេចរហូតដល់ចំណុចក្រោយនាគព័ន្ធ សង្កាត់អូរឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញនោះ សមត្ថកិច្ចបានអះអាងថាជនជាប់ចោទឈ្មោះ [redacted] វេង បានបាញ់មកលើសមត្ថកិច្ចចំនួន០៥គ្រាប់តែពុំត្រូវ ហើយសមត្ថកិច្ចបានបាញ់ចំនួន០២គ្រាប់តបទៅវិញ ប៉ុន្តែជនជាប់ចោទបានបដិសេធថាខ្លួនពុំបានបាញ់នោះទេ គឺសមត្ថកិច្ចទេដែលបានបាញ់មកលើខ្លួន ដូច្នេះឃើញថាការអះអាងរបស់ សមត្ថកិច្ច និង ការអះអាងរបស់ជនជាប់ចោទមានភាពផ្ទុយគ្នា ។

៧-ប្រសិនបើជនជាប់ចោទឈ្មោះ [redacted] វេង បានបាញ់ដូចការអះអាងចោទប្រកាន់របស់សមត្ថកិច្ចក៏ដោយក៏ជនជាប់ចោទគ្រាន់ តែបានបាញ់ឡើងលើជាការគំរាម កុំអោយអ្នកជិះម៉ូតូដេញតាមខ្លួនអោយឈប់ដេញតាមទៀត ឬក៏ជនជាប់ចោទពុំបានបាញ់សំដៅអ្នកដេញតាមខ្លួននោះឡើយ ដែលករណីនេះស្ថិតនៅជាវិមតិសង្ស័យនៅឡើយ ដែលវិមតិសង្ស័យនេះត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

៨-ក្រោយពេលកើតហេតុ សមត្ថកិច្ចក៏ដូចជាអ្នកជំនាញពុំបានប្រមូលវត្ថុតាំង ដូចជាសំបកគ្រាប់, ក្បាលគ្រាប់ ឬស្លាកស្នាមផ្សេងពីកន្លែងកើតហេតុទេ ហើយមកដល់ពេលនេះមានរយៈពេលជាង៥(ប្រាំ)ឆ្នាំ



Scanned with CamScanner

ហើយដែលវត្ថុតាងត្រូវបាត់បង់មិនអាចប្រមូលបាននោះទេ ។ ដូច្នេះលទ្ធភាពនៃការស៊ើបអង្កេតលើវត្ថុតាងនេះពុំអាចធ្វើបាននោះឡើយ ។

៥-គ្មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់ លើសពីវិមតិសង្ស័យក្នុងការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វេង ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅចំណុចក្រោយនាគព័ន្ធ សង្កាត់ អូរឬស្សីទី៤ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧-១២-២០០៨ ឡើយ ដែលគប្បីអោយឈ្មោះ [redacted] វេងនេះរួចខ្លួនពីបទចោទប្រកាន់នេះ ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ៩៦៩ ចុះថ្ងៃទី០៤-១១-២០១៣ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខៈ២៣៨ ចុះថ្ងៃទី២៧-០៩-២០១៣ របស់តុលាការកំពូល ។

~~២-អោយឈ្មោះ~~ [redacted] វេង ហៅ លី សុខហេង ហៅ លឹម វេង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅកំណើតស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅមុនពេលចាប់ខ្លួនផ្ទះជួល ផ្លូវនរោត្តមសង្កាត់ទន្លេ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ។ រួចខ្លួនពីបទចោទប្រកាន់ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅចំណុចក្រោយនាគព័ន្ធ សង្កាត់អូរឬស្សីទី៤ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧-១២-២០០៨ ។

៣-សាលដីការនេះជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 22 ខែ 5 ឆ្នាំ២០14
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

២៥



Scanned with CamScanner